ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

លេខៈ ៦១១១ សក.៥៥

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ 200៨

## ជំរាបមក

## លោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង

**កម្មវត្ថុ:** ស្តីពីការអនុវត្តន៏តម្លៃថ្មីលើការផលិតផ្លាកលេខ ប័ណ្ណសម្គាល់យានយន្ត ប័ណ្ណបើកបរយានយន្ត និង សេវាប្រឡងយកប័ណ្ណបើកបរយានយន្ត ។

**យោងៈ** -លិខិតលេខ ១៣៦៥ សជណ.គប ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-កិច្ចសន្យាលេខ២១៤សក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ស្តីពីការវិនិយោគផលិតផ្លាកលេខ ប័ណ្ណសម្គាល់យានយន្ត ប័ណ្ណបើកបរ និងរៀបចំកន្លែងប្រឡងយកប័ណ្ណបើកបរយានយន្តគ្រប់ប្រភេទ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងសាធារណការ និងដឹកជញ្ជូនសូមជំរាប លោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុងជ្រាបថាៈ ក្រសួងបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនកាំត្រង់ស៊ីប ឱ្យធ្វើវិនិយោគផលិតផ្លាកលេខ ប័ណ្ណសម្គាល់ ប័ណ្ណបើកបរ សម្រាប់យានយន្តគ្រប់ប្រភេទ សាងសង់អគារប្រឡងផ្នែកទ្រឹស្តី និងទីលានប្រឡងផ្នែកដៃចង្កូតទៅតាមប្រព័ន្ធបច្ចេកវិទ្យា និងព័ត៌មានវិទ្យាទំនើប ។ ន័យដូចបានជំរាបជូនខាងលើនេះ ដើម្បីអនុវត្តន៏នូវកិច្ចសន្យានោះ ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការណែនាំដល់លោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង នូវវិធានការមួយចំនួន ដូចខាងក្រោម :

១- តម្លៃថ្មីដែលមានចែងក្នុងកិច្ចសន្យានេះក្នុងការផលិតផ្លាកលេខ ប័ណ្ណសម្គាល់ ប័ណ្ណបើកបរយានយន្ត និងសេវាប្រឡងយកប័ណ្ណបើកបរយានយន្តគ្រប់ប្រភេទត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៨ តទៅ ។

២- ថ្លៃទូទាត់ផលិតផ្លាកលេខ ប័ណ្ណសម្គាល់ និងប័ណ្ណបើកបរយានយន្ត មានដូចខាងក្រោម :

| | |
|---|---|
| -ផ្លាកលេខទោចក្រយានយន្ត ឬត្រីចក្រយានយន្ត | ៥.៧២០ ដុល្លា |
| -ផ្លាកលេខរថយន្តធុនតូច | ១៧.១៦០ ដុល្លា |
| -ផ្លាកលេខរថយន្តធុនធំ | ២០.០២០ ដុល្លា |
| -ប័ណ្ណសម្គាល់យានយន្ត ឬប័ណ្ណបើកបរយានយន្ត | ៦.១៤៥ ដុល្លា ។ |

៣- ថ្លៃសេវាប្រឡងយកប័ណ្ណបើកបរយានយន្ត មានដូចខាងក្រោម :

| | |
|---|---|
| -ទោចក្រយានយន្ត ឬត្រីចក្រយានយន្ត | ៦.៨៦៤ ដុល្លា |

-រថយន្តធុនទេសចរណ៍ ១៤.០១៤ ដុល្លា

-រថយន្តធុនធំ ១៦.៨៧៥ ដុល្លា

-រថយន្តសណ្តោង ២២.៩៥៤ ដុល្លា ។

៤- មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ត្រូវធ្វើការទូទាត់ និងសេវាដូចមានចែងក្នុងចំណុចទី២ និងទី៣ខាងលើ នៅអគ្គនាយកដ្ឋានដឹកជញ្ជូន ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមលោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុងជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រដ្ឋមន្ត្រី

ស៊ុន-ចាន់ថុល

**ចម្លងជូន :**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលាខេត្ត ក្រុង
" ដើម្បីជូនជ្រាប "
-ឯកសារ កាលប្បវត្តិ